សំណើ
# 20 ដាក់កម្រិតការដោះលែងដោយមានលក្ខខណ្ឌសម្រាប់បទល្មើសមួយចំនួន ដោយបច្ចុប្បន្នបានចាត់ទុកថាជាជនល្មើសច្បាប់ដែលមិនប្រើហិង្សា។ អនុញ្ញាតឲ្យមានការកាត់ទោសបទឧក្រិដ្ឋសម្រាប់បទល្មើសមួយចំនួន ដែលបច្ចុប្បន្នត្រូវបានគេចាត់ទុកថាជា បទល្មើសមជ្ឈិម។ បញ្ញត្តិផ្តួចផ្តើម ៖

**ចំណងជើង និងសេចក្តីសង្ខេបជាផ្លូវការ** រៀបចំដោយអគ្គមេធាវី

**អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័ររដ្ឋលេខាធិការនៅ *voterguide.sos.ca.gov*។**

- កំណត់សិទ្ធិទទួលបានកម្មវិធីដោះលែងដោយមានលក្ខខណ្ឌ ដែលបានបង្កើនឡើងសម្រាប់ជនល្មើសដែលមិនប្រើហិង្សា ដែលបានបំពេញរយៈពេលជាប់ទោសដំបូងរបស់ពួកគេ ដោយលុបបំបាត់នូវសិទ្ធិទទួលបានសម្រាប់បទល្មើសមួយចំនួន។
- ផ្លាស់ប្តូរស្តង់ដារ និងតម្រូវការនានា ដែលគ្រប់គ្រងការសម្រេចលើការដោះលែងដោយមានលក្ខខណ្ឌក្រោមកម្មវិធីនេះ។
- អនុញ្ញាតឲ្យមានការចោទប្រកាន់ពីបទឧក្រិដ្ឋសម្រាប់ចោរកម្មជាក់លាក់ ដែលបច្ចុប្បន្នអាចចោទប្រកាន់បានតែបទល្មើសមជ្ឈិម រាប់បញ្ចូលទាំងអំពើចោរកម្មមួយចំនួន ដែលមានតម្លៃចម្លោះពី $250 ទៅ $950។
- តម្រូវឲ្យបុគ្គលដែលជាប់ទោសពីបទមជ្ឈិមជាក់លាក់ណាមួយ ធ្វើការបញ្ជូនសំណាក DNA សម្រាប់រក្សាទុកក្នុងប្រព័ន្ធទិន្នន័យរដ្ឋ។

**សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគច្បាប់ស្តីពីផលប៉ះពាល់សារពើពន្ធរបស់រដ្ឋនិងរដ្ឋាភិបាលមូលដ្ឋាន ៖**

- បង្កើនការចំណាយលើមន្ទីរកែប្រែរដ្ឋ និងមូលដ្ឋាន ដែលទំនងជាមានរាប់សិបលានដុល្លារក្នុងមួយឆ្នាំ សំខាន់ដោយមូលហេតុកំណើនអ្នកជាប់ពន្ធនាគារក្នុងខោនធី និងកម្រិតត្រួតពិនិត្យរបស់សហគមន៍។
- បង្កើនការចំណាយដែលទាក់ទងនឹងតុលាការរដ្ឋ និងមូលដ្ឋាន ដែលអាចមានចំនួនជាងពីរបីលានដុល្លារក្នុងមួយឆ្នាំ។
- បង្កើនការចំណាយលើទីភ្នាក់ងារអនុវត្តន៍ច្បាប់រដ្ឋ និងមូលដ្ឋាន មិនទំនងជាលើសពីពីរបីលានដុល្លារក្នុងមួយឆ្នាំ ទាក់ទងនឹងការប្រមូល និងដំណើរការសំណាក DNA។

20

**ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ**

## ទិដ្ឋភាពទូទៅ

សំណើប្រជាមតិ 20 មានបទបញ្ញត្តិចម្បងចំនួនបួន។ វា៖

- ផ្លាស់ប្តូរច្បាប់រដ្ឋដើម្បីបង្កើនការដាក់ទោសបញ្ញត្តិព្រហ្មទណ្ឌសម្រាប់បទល្មើសដែលទាក់ទងនឹងចោរកម្មមួយចំនួន។
- ផ្លាស់ប្តូររបៀបដែលមនុស្សដែលត្រូវបានដោះលែងចេញពីពន្ធនាគាររដ្ឋត្រូវបានត្រួតពិនិត្យនៅក្នុងសហគមន៍។
- ធ្វើការផ្លាស់ប្តូរមួយចំនួនទៅលើដំណើរការដែលត្រូវបានបង្កើតឡើងដោយសំណើប្រជាមតិ 57 (2016) សម្រាប់ការពិចារណាការដោះលែងអ្នកទោសចេញពីពន្ធនាគារ។
- តម្រូវឲ្យភ្នាក់ងារអនុវត្តច្បាប់រដ្ឋ និងក្នុងមូលដ្ឋានប្រមូល DNA ពីមនុស្សពេញវ័យដែលត្រូវបានផ្តន្ទាទោសពីបទល្មើសមួយចំនួន។

ខាងក្រោមនេះ យើងពិភាក្សាអំពីបទបញ្ញត្តិនីមួយៗក្នុងចំណោមបទបញ្ញត្តិចម្បងៗទាំងនេះ និងបរិយាយអំពីផលប៉ះពាល់សារពើពន្ធនៃសំណើប្រជាមតិនេះ។

## ទោសបញ្ញត្តិព្រហ្មទណ្ឌសម្រាប់បទល្មើសមួយចំនួនដែលទាក់ទងនឹងចោរកម្ម

### ជីវប្រវត្តិ

បទឧក្រិដ្ឋ គឺជាប្រភេទធ្ងន់ធ្ងរបំផុតនៃបទល្មើស។ ច្បាប់រដ្ឋ កំណត់និយមន័យបទឧក្រិដ្ឋខ្លះថាមានលក្ខណៈ "ហិង្សា" ឬ "ធ្ងន់ធ្ងរ" ឬទាំងពីរ។ ឧទាហរណ៍នៃបទឧក្រិដ្ឋដែលត្រូវបានកំណត់និយមន័យថាហិង្សា និងធ្ងន់ធ្ងររួមមានមនុស្សឃាតការប្លន់និងការរំលោភសេពសន្ថវៈ។ បទឧក្រិដ្ឋដែលមិនត្រូវបានកំណត់និយមន័យថាហិង្សា ឬធ្ងន់ធ្ងររួមមានការជួញដូរមនុស្ស និងការលក់គ្រឿងញៀន។

### ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

បន្ត

បទមជ្ឈិម គឺជាបទល្មើសដែលមានលក្ខណៈមិនសូវធ្ងន់ធ្ងរ។ បទមជ្ឈិម រួមមានបទល្មើសដូចជាការបង្ករបួសស្នាម និងការស្រវឹងនៅទីសាធារណៈ។

***ការសម្រេចផ្តន្ទាទោសបទឧក្រិដ្ឋ។*** ជនល្មើសដែលបានប្រព្រឹត្តបទឧក្រិដ្ឋ អាចត្រូវបានកាត់សេចក្តីដូចខាងក្រោម៖

- ***ពន្ធនាគាររដ្ឋ។*** ជនដែលការផ្តន្ទាទោសពេលបច្ចុប្បន្ន ឬពីអតីតកាលរបស់ពួកគេរួមមានបទល្មើសធ្ងន់ធ្ងរ ហិង្សា ឬផ្លូវភេទ អាចត្រូវបានសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររដ្ឋ។
- ***ពន្ធនាគារនៃខោនធី និង/ឬ ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងសហគមន៍។*** ជនដែលពុំមានការផ្តន្ទាទោសបច្ចុប្បន្ន ឬពីអតីតកាលសម្រាប់បទល្មើសកម្រិតធ្ងន់ធ្ងរ ហិង្សា ឬផ្លូវភេទ ជាទូទៅត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារខោនធី ឬត្រូវបានត្រួតពិនិត្យដោយមន្ត្រីគ្រប់គ្រងការដោះលែងសាកល្បងនៃខោនធីនៅក្នុងសហគមន៍ ឬទាំងពីរ។

***ការកាត់ទោសបទមជ្ឈិម។*** ជនល្មើសដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម អាចត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារនៃខោនធី ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងសហគមន៍ប្រចាំខោនធី ការផាកពិន័យ ឬរួមបញ្ចូលគ្នាទាំងបីនេះ។ ជាទូទៅ ជនល្មើសទាំងនេះត្រូវបានផ្តន្ទាទោសស្រាលជាងជនល្មើសបទឧក្រិដ្ឋ។ ឧទាហរណ៍ បទមជ្ឈិមត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអតិបរមាមួយឆ្នាំ រីឯជនល្មើស នៃបទឧក្រិដ្ឋអាចត្រូវដាក់ទោសជាប់ពន្ធនាគារយូរជាងនេះ។ បន្ថែមពីនេះទៀត ជនល្មើសដែលបានប្រព្រឹត្តបទមជ្ឈិម ជាទូទៅត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងសហគមន៍រយៈពេលតិចឆ្នាំជាង ហើយអាចមិនត្រូវបានត្រួតពិនិត្យជាប់លាប់ពេកដោយមន្ត្រីគ្រប់គ្រងការដោះលែងសាកល្បងទេ។

***ការសម្រេចផ្តន្ទាទោសពីបទ Wobbler។*** បច្ចុប្បន្ននេះ បទល្មើសមួយចំនួន—ដូចជាការលួចអត្តសញ្ញាណ—អាចត្រូវបានដាក់ទោសដូចគ្នានឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែរ។ បទល្មើសទាំងនេះហៅថា "wobbler"។ ជាទូទៅសេចក្តីសម្រេចគឺផ្អែកទៅលើភាពជាក់លាក់នៃឧក្រិដ្ឋកម្ម និងប្រវត្តិបទល្មើសរបស់ជនណាម្នាក់។

***សំណើប្រជាមតិ 47 ការសម្រាលទោសសម្រាប់បទល្មើសមួយចំនួន។*** កាលពីខែវិច្ឆិកា ឆ្នាំ 2014 អ្នកបោះឆ្នោតបានអនុម័តសំណើប្រជាមតិ 47 ដែលបណ្តាលឲ្យមានបទល្មើសទាក់ទងនឹងចោរកម្មមួយចំនួន ដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិមជំនួសឲ្យបទឧក្រិដ្ឋ។ ឧទាហរណ៍ ក្រោមសំណើប្រជាមតិ 47 ចោរកម្មដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ដែលមានតម្លៃ $950 ឬតិចជាងនេះ ជាទូទៅត្រូវបានចាត់ទុកថាជាចោរកម្មកម្រិតស្រាល ហើយត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម—ជាជាងបទឧក្រិដ្ឋ ដែលពេលខ្លះកាលពីមុនអាចត្រូវផ្តន្ទាទោសជាចោរកម្មកម្រិតធ្ងន់ (ដូចជា ប្រសិនបើរថយន្តមានគេលួច)។ សំណើប្រជាមតិ 47 ជាទូទៅក៏តម្រូវផងដែរថា ការលួចឥវ៉ាន់ក្នុងហាងដែលមានតម្លៃ $950 ឬតិចជាងនេះ អាចត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម—ជាជាងបទឧក្រិដ្ឋ ដែលកាលពីមុនអាចត្រូវបានផ្តន្ទាទោសជាបទឧក្រិដ្ឋ។

## សំណើ

***បង្កើនទោសទណ្ឌសម្រាប់បទល្មើសមួយចំនួនដែលពាក់ព័ន្ធនឹងចោរកម្ម។*** សំណើប្រជាមតិ 20 បង្កើតបទល្មើសពាក់ព័ន្ធនឹងចោរកម្មថ្មីចំនួនពីរ៖

- ***ចោរកម្មសៀរៀល។*** ជនល្មើសណាម្នាក់ដែលមានការផ្តន្ទាទោសពីមុនចំនួនពីរដង ឬច្រើនជាងនេះសម្រាប់បទល្មើសមួយចំនួនដែលពាក់ព័ន្ធនឹងចោរកម្ម (ដូចជាការលបចូលលួច ការផលិតក្រដាសប្រាក់ក្លែងក្លាយ ឬការប្លន់ឡាន) ដែលត្រូវបានរកឃើញថាមានកំហុសពីបទលួចឥវ៉ាន់ក្នុងហាង ឬចោរកម្មខ្នាតតូចដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិមានតម្លៃលើសពី $250 អាចត្រូវបានចោទប្រកាន់ពីបទចោរកម្មសៀរៀល។
- ***ចោរកម្មនៅហាងលក់រាយដោយមានការត្រៀមទុក។*** ជនណាម្នាក់ដែលចូលដៃចូលជើងជាមួយជនដទៃទៀតដែលប្រព្រឹត្តអំពើចោរកម្មខ្នាតតូច ឬលួចឥវ៉ាន់ក្នុងហាងពីរដង ឬច្រើនជាងនេះ ដែលតម្លៃសរុបនៃទ្រព្យសម្បត្តិដែលបានលួចក្នុងរយៈពេល 180 ថ្ងៃ លើសពី $250 អាចត្រូវបានចោទប្រកាន់ពីបទចោរកម្មនៅហាងលក់រាយដោយមានការត្រៀមទុក។

បទល្មើសថ្មីទាំងពីរនេះ អាចជាបទល្មើស wobblers ដែលត្រូវផ្តន្ទាទោសដោយដាក់ពន្ធនាគារក្នុងខោនធីរហូតដល់បីឆ្នាំទោះបីជាជនល្មើសនោះមានការផ្តន្ទាទោសពីមុ

20

នមកសម្រាប់បទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ ហិង្សា ឬផ្លូវភេទក៏ដោយ។

បន្ថែមពីលើនេះទៀត សំណើប្រជាមតិ 20 អនុញ្ញាតឲ្យបទល្មើសដែលពាក់ព័ន្ធនឹងចោរកម្មដែលមានស្រាប់ទាំងឡាយ ដែលជាទូទៅត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ក្រោមសំណើប្រជាមតិ 47 ត្រូវបានផ្តន្ទាទោសជាបទឧក្រិដ្ឋវិញ។ ឧទាហរណ៍ អនុលោមតាមច្បាប់បច្ចុប្បន្ន ចោរកម្មទ្រព្យសម្បត្តិទាំងអស់ដែលមានតម្លៃតិចជាង $950 ពីហាងណាមួយ ជាទូទៅតម្រូវឲ្យផ្តន្ទាទោសជាបទមជ្ឈិម។ អនុលោមតាមសំណើប្រជាមតិ 20 ជនល្មើសដែលលួចទ្រព្យសម្បត្តិមានតម្លៃតិចជាង $950 ដែលមិនមែនសម្រាប់ដាក់លក់ (ដូចជា ម៉ាស៊ីនគិតប្រាក់) ពីហាងណាមួយ អាចទទួលបានការកាត់ទោសជាបទឧក្រិដ្ឋ។ សំណើនេះអាចបង្កើនថេរវេលាដែលជនល្មើសត្រូវបានផ្តន្ទាទោសពីបទល្មើសទាំងនេះ។ ឧទាហរណ៍ ជាជាងការទទួលទោសរហូតដល់ប្រាំមួយខែនៅក្នុងពន្ធនាគារនៃខោនធី ពួកគេអាចនឹងទទួលទោសរហូតដល់បីឆ្នាំនៅក្នុងពន្ធនាគារខោនធី ឬពន្ធនាគាររបស់រដ្ឋ។

យើងប៉ាន់ស្មានថា មនុស្សប្រមាណពីរបីពាន់នាក់អាចរងផលប៉ះពាល់ពីការផ្លាស់ប្តូរខាងលើជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាងណា ការប៉ាន់ស្មាននេះផ្អែកទៅលើទិន្នន័យរកបានដែលនៅមានកម្រិត ហើយចំនួនមនុស្សជាក់ស្តែងដែលរងផលប៉ះពាល់ នឹងអាស្រ័យទៅលើជម្រើសទាំងឡាយដែលធ្វើឡើងដោយរដ្ឋអាជ្ញា ឬចៅក្រម។ ជាលទ្ធផល ចំនួនជាក់ស្តែងអាចនឹងកើនឡើង ឬថយចុះខ្លាំង។

## ការអនុវត្តការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងសហគមន៍

### សាវតា

ជនល្មើសដែលត្រូវបានដោះលែងពីពន្ធនាគាររដ្ឋ ក្រោយពីបានទទួលទោសបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ ឬហិង្សា ត្រូវដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យមួយរយៈនៅក្នុងសហគមន៍ដោយទីភ្នាក់ងារគ្រប់គ្រងការដោះ លែងនៅក្រៅឃុំមានលក្ខខណ្ឌរបស់រដ្ឋ។ ជនល្មើសដែលត្រូវបានដោះលែងពីពន្ធនាគាររដ្ឋ ក្រោយពីបានទទួលទោសសម្រាប់បទល្មើសផ្សេងៗ ជាធម្មតាត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងសហគមន៍ដោយមន្ត្រីគ្រប់គ្រងការដោះលែងសាកល្បងប្រចាំខោនធី—ជាទូទៅហៅថា ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងសហគមន៍ក្រោយការដោះលែង (PRCS)។ នៅពេលជនល្មើសដែលស្ថិតក្រោមការដោះលែងមានលក្ខខណ្ឌរដ្ឋ ឬ PRCS បំពានវិធានទាំងឡាយដែលតម្រូវឲ្យគោរពតាមអំឡុងពេលស្ថិតក្រោមការត្រួតពិនិត្យ—ហៅថា ការបំពាន "លក្ខខណ្ឌនៃការត្រួតពិនិត្យរបស់ពួកគេ"—ភ្នាក់ងារគ្រប់គ្រងការដោះលែងមានលក្ខខណ្ឌរបស់រដ្ឋ ឬមន្ត្រីគ្រប់គ្រងការដោះលែងសាកល្បងនៃខោនធី អាចជ្រើសរើសធ្វើការស្នើសុំឲ្យចៅក្រមផ្លាស់ប្តូរលក្ខខណ្ឌនៃការត្រួតពិនិត្យរបស់ពួកគេ។ សំណើនេះអាចបណ្តាលឲ្យមានលក្ខខណ្ឌ ឬការដាក់ពន្ធនាគារខោនធីកាន់តែឃោរឃៅ។

### សំណើ

***ផ្លាស់ប្តូរការអនុវត្តការត្រួតពិនិត្យនៅក្នុងសហគមន៍។*** សំណើប្រជាមតិនេះ ធ្វើការផ្លាស់ប្តូរជាច្រើនទៅលើការអនុវត្តការដោះលែងនៅក្រៅឃុំមានលក្ខខណ្ឌរបស់រដ្ឋ និង PRCS ។ ឧទាហរណ៍ វាតម្រូវឲ្យមន្ត្រីគ្រប់គ្រងការដោះលែងសាកល្បងស្នើឲ្យចៅក្រមផ្លាស់ប្តូរលក្ខខណ្ឌនៃការត្រួតពិនិត្យសម្រាប់ជនល្មើសដែលកំពុងស្ថិតក្រោម PRCS ប្រសិនបើពួកគេបានបំពានជាលើកទីបី។ បន្ថែមពីលើនេះទៀត សំណើប្រជាមតិនេះតម្រូវឲ្យនាយកដ្ឋានគ្រប់គ្រងការដោះលែងនៅក្រៅឃុំមានលក្ខខណ្ឌរដ្ឋ និងផ្នែកគ្រប់គ្រងការដោះលែងសាកល្បងដោះដូរព័ត៌មានបន្ថែមអំពីជនល្មើសដែលពួកគេត្រួតពិនិត្យ។

## សំណើប្រជាមតិ 57 ដំណើរការពិចារណាលើការដោះលែង

### សាវតា

ជនល្មើសនៅក្នុងពន្ធនាគារ

ត្រូវបានផ្តន្ទាទោសពីបទល្មើសបឋម។ ជាទូទៅ នេះគឺជាបទល្មើសដែលពួកគេត្រូវទទួលទោសនៅក្នុងពន្ធនាគាររយៈពេលយូរបំផុត។ ជារឿយៗ ពួកគេទទួលទោសក្នុងរយៈពេលបន្ថែមទៅតាមអង្គហេតុនៃរឿងក្តីរបស់ពួកគេ (ដូចជា ប្រសិនបើពួកគេបានប្រើប្រាស់កាំភ្លើង) ឬសម្រាប់អង្គហេតុផ្សេងទៀត បទល្មើសតិចជាងនេះ ដែលពួកគេត្រូវបានផ្តន្ទាទោសនៅក្នុងពេលដូចគ្នានោះ។

20

**ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ** បន្ត

ឧទាហរណ៍ ជនល្មើសដែលពីមុនមកត្រូវបានផ្តន្ទាទោសពីបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ ឬហិង្សា ជាទូទៅត្រូវតែទទួលទោសរយៈពេលយូរជាងពីរដងសម្រាប់បទឧក្រិដ្ឋថ្មីណាមួយដែលពួកគេប្រព្រឹត្ត។

កាលពីខែវិច្ឆិកា ឆ្នាំ 2016 អ្នកបោះឆ្នោតបានអនុម័តសំណើប្រជាមតិ 57 ដែលផ្លាស់ប្តូររដ្ឋធម្មនុញ្ញរបស់រដ្ឋ ដើម្បីធ្វើឲ្យអ្នកទោសក្នុងពន្ធនាគារ ដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋអហិង្សា មានសិទ្ធិទទួលបានការពិចារណាឲ្យដោះលែងក្រោយពីបានទទួលទោសសម្រាប់បទល្មើសបឋមរបស់ពួកគេរួច។ អ្នកទោស ត្រូវបានពិចារណាសម្រាប់ការដោះលែងដោយគណៈសវនាការដោះលែងនៅក្រៅឃុំដោយមានលក្ខខណ្ឌ (BPH) របស់រដ្ឋ។ ជាពិសេស សមាជិកបុគ្គលិក BPH ពិនិត្យឡើងវិញទៅលើព័ត៌មានផ្សេងៗនៅក្នុងសំណុំឯកសាររបស់អ្នកទោសដែលនៅជាមួយគ្នាដូចជា ប្រវត្តិបទល្មើស និងអាកប្បកិរិយានៅក្នុងពន្ធនាគារ ដើម្បីកំណត់ថាតើអ្នកទោសដែលនៅជាមួយគ្នានោះនឹងត្រូវបានដោះលែងដែរឬទេ។ BPH ក៏ពិចារណាទៅលើរាល់លិខិតទាំងឡាយណាដែលបានដាក់ស្នើដោយរដ្ឋអាជ្ញា ទីភ្នាក់ងារអនុវត្តច្បាប់ និងជនរងគ្រោះអំពីអ្នកទោសផងដែរ។ ក្រសួងកែប្រែ និងស្តារនីតិសម្បទារដ្ឋ California (CDCR) ទាក់ទងជនរងគ្រោះដែលបានចុះបញ្ជីជាមួយរដ្ឋ ដើម្បីជូនដំណឹងដល់ពួកគេថាពួកគេអាចដាក់ស្នើលិខិតទាំងនេះបាន។ អ្នកទោសត្រូវបានដោះលែង លើកលែងតែ BPH សម្រេចថា អ្នកទោសនោះបង្កហានិភ័យនៃអំពើហិង្សាដែលមិនសមហេតុផល។ ប្រសិនបើមិនត្រូវបានដោះលែងទេនោះ អ្នកទោសអាចស្នើសុំការពិនិត្យឡើងវិញទៅលើសេចក្តីសម្រេច។ អ្នកទោសដែលត្រូវបានបដិសេធការដោះលែង ត្រូវបានពិចារណាឡើងវិញនៅឆ្នាំបន្ទាប់ ទោះបីជារឿយៗពួកគេបំពេញការកាត់ទោសរបស់ពួកគេ ហើយត្រូវបានដោះលែងមុនពេលនោះក៏ដោយ។ នៅឆ្នាំ 2019 BPH បានពិចារណាទៅលើអ្នកទោសចំនួនជិត 4,600 នាក់ ហើយបានអនុម័តប្រហែល 860 (19 ភាគរយ) សម្រាប់ការដោះលែង។

## សំណើ

***ផ្លាស់ប្តូរសំណើប្រជាមតិ 57 ដំណើរការពិចារណាលើការដោះលែង។*** សំណើប្រជាមតិ 20 ធ្វើការផ្លាស់ប្តូរជាច្រើនទៅលើដំណើរការពិចារណាការដោះលែងក្នុងសំណើប្រជាមតិ 57។ ការផ្លាស់ប្តូរចម្បងៗគឺ៖

- ដកអ្នកទោសមួយចំនួនចេញពីដំណើរការ—ដូចជា អ្នកទោសដែលត្រូវបានផ្តន្ទាទោសប្រភេទមួយចំនួនដែលជាការបង្ករបួសស្នាម និងអំពើហិង្សាក្នុងគ្រួសារ។
- តម្រូវឲ្យ BPH បដិសេធការដោះលែងអ្នកទោសដែលបង្កហានិភ័យមិនសមហេតុផលនៃការប្រព្រឹត្តបទឧក្រិដ្ឋដែលបណ្តាលឲ្យមានជនរងគ្រោះ ជាជាងគ្រាន់តែដោះលែងអ្នកទោសដែលបង្កហានិភ័យមិនសមហេតុផលនៃអំពើហិង្សា។
- តម្រូវឲ្យ BPH ពិចារណាលើបញ្ហាបន្ថែមដូចជា ឥរិយាបថរបស់អ្នកទោសអំពីបទល្មើសរបស់ពួកគេ នៅពេលសម្រេចថាតើត្រូវដោះលែងពួកគេដែរឬទេ។
- តម្រូវឲ្យអ្នកទោស ដែលត្រូវបានបដិសេធការដោះលែង រង់ចាំរយៈពេលពីរឆ្នាំ (ជាជាងមួយឆ្នាំ) មុនពេលទទួលបានការពិចារណាឡើង វិញដោយ BPH។
- អនុញ្ញាតឲ្យរដ្ឋអាជ្ញាស្នើសុំឲ្យ BPH ធ្វើការពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចអំពីការដោះលែង។
- តម្រូវឲ្យ CDCR ព្យាយាមកំណត់រកទីតាំងជនរងគ្រោះ ដើម្បីជូនដំណឹងដល់ពួកគេអំពីការពិនិត្យឡើងវិញ សូម្បីតែពួកគេពុំបានចុះឈ្មោះជាមួយរដ្ឋក៏ដោយ។

# ការប្រមូល DNA

## សាវតា

នៅ California សំណាក DNA ត្រូវតែផ្តល់ដោយ (1) មនុស្សពេញវ័យដែលត្រូវបានចាប់ ខ្លួនចោទប្រកាន់ ឬផ្តន្ទាទោសពីបទឧក្រិដ្ឋ (2) យុវជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ និង (3) ជនដែលត្រូវបានតម្រូវឲ្យចុះឈ្មោះថាជាជនល្មើសផ្លូវភេទ ឬដុតបំផ្លាញទ្រព្យសម្បត្តិ។ សំណាកទាំងនេះត្រូវបានប្រមូលដោយទីភ្នាក់ងារអនុវត្តច្បាប់រដ្ឋ និងក្នុងមូលដ្ឋាន និងដាក់ជូនក្រសួងយុត្តិធម៌រដ្ឋ California (DOJ) សម្រាប់ការដំណើរការ។ DOJ បច្ចុប្បន្ននេះ ទទួលបានសំណាក DNA ប្រមាណ 100,000 ជារៀងរាល់ឆ្នាំ។ DOJ រក្សាទុកប្រវត្តិ DNA នៅក្នុងមូលដ្ឋានទិន្នន័យ DNA ទូទាំងរដ្ឋ

20

និងដាក់ជូនវាទៅកាន់មូលដ្ឋានទិន្នន័យជាតិ។ មូលដ្ឋានទិន្នន័យទាំងនេះ ត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារអនុវត្តច្បាប់ដើម្បីស៊ើបអង្កេតបទល្មើស។

### សំណើ

***ពង្រីកការប្រមូល DNA ។*** សំណើប្រជាមតិនេះ តម្រូវឲ្យទីភ្នាក់ងារអនុវត្តន៍ច្បាប់រដ្ឋ និងក្នុងមូលដ្ឋាន ប្រមូលសំណាក DNA ផងដែរពីមនុស្សពេញវ័យ ដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមមួយចំនួន។ បទល្មើសទាំងនេះរួមមាន ការលួចឥវ៉ាន់ក្នុងហាង ការក្លែងបន្លំក្រដាសប្រាក់ និងបទល្មើសហិង្សាក្នុងគ្រួសារមួយចំនួន។

## ផលប៉ះពាល់សារពើពន្ធ

សំណើប្រជាមតិនេះ នឹងមានផលប៉ះពាល់សារពើពន្ធជាច្រើនទៅលើរដ្ឋាភិបាលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។ ទោះជាយ៉ាងណា ទំហំជាក់លាក់នៃផលប៉ះពាល់ដែលពិភាក្សាខាងក្រោមនេះ នឹងអាស្រ័យទៅលើកត្តាជាច្រើន។ កត្តាសំខាន់មួយ អាចជាសេចក្តីសម្រេចទាំងឡាយដែលត្រូវបានធ្វើឡើងដោយតុលាការ និងផ្នែកដទៃទៀត (ដូចជា នាយកដ្ឋានគ្រប់គ្រងការដោះលែងសាកល្បងនៃខោនធី និងរដ្ឋអាជ្ញា) អំពីរបៀបដែលសំណើប្រជាមតិនឹងត្រូវបានអនុវត្ត។ ឧទាហរណ៍ សំណើប្រជាមតិស្វែងរកការផ្លាស់ប្តូរសិទ្ធិរដ្ឋធម្មនុញ្ញាមួយចំនួនរបស់អ្នកទោសឲ្យទទួលបានការពិចារណាសម្រាប់ការដោះលែងក្រោមសំណើប្រជាមតិ 57 ដោយពុំមានការផ្លាស់ប្តូររដ្ឋធម្មនុញ្ញរបស់រដ្ឋ។ ប្រសិនបើសំណើប្រជាមតិត្រូវជួបបញ្ហាប្រឈមនៅក្នុងតុលាការនោះ ចៅក្រមអាចកាត់សេចក្តីថា បទបញ្ញត្តិមួយចំនួនមិនអាចដាក់ចូលជាធរមានបានឡើយ។ ការប៉ាន់ស្មានរបស់យើងខាងក្រោមអំពីផលប៉ះពាល់សារពើពន្ធទៅលើរដ្ឋាភិបាលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានសន្មតថា សំណើប្រជាមតិនេះត្រូវបានអនុវត្តយ៉ាងពេញលេញ។ សរុបមក កំណើនត្រូវបានប៉ាន់ស្មានអំពីបន្ទុកចំណាយរបស់រដ្ឋឆ្លុះបញ្ចាំងឲ្យឃើញតិចជាងមួយភាគរយនៃកញ្ចប់ថវិកាមូលនិធិទូទៅបច្ចុប្បន្នរបស់រដ្ឋ។ (មូលនិធិទូទៅគឺជាគណនីប្រតិបត្តិការចម្បងរបស់រដ្ឋដែលវាប្រើប្រាស់ក្នុងការទូទាត់សម្រាប់វិស័យអប់រំ ពន្ធនាគារ ការថែទាំសុខភាព និងសេវាកម្មផ្សេងៗ។)

***បន្ទុកចំណាយកែប្រែនៅថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។*** សំណើប្រជាមតិនេះនឹងបង្កើនបន្ទុកចំណាយកែប្រែនៅថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានតាមវិធីបីយ៉ាង។

- ទីមួយ កំណើនទោសបញ្ញត្តិសម្រាប់បទល្មើសដែលពាក់ព័ន្ធនឹងចោរកម្ម អាចនឹងបង្កើនការចំណាយកែប្រែ ភាគច្រើនដោយការបង្កើនចំនួនអ្នកជាប់ពន្ធនាគារខោនធី និងកម្រិតនៃការត្រួតពិនិត្យនៅក្នុងខោនធីសម្រាប់មនុស្សមួយចំនួន។
- ទីពីរ ការផ្លាស់ប្តូរទៅលើការអនុវត្តការត្រួតពិនិត្យនៅក្នុងសហគមន៍ អាចនឹងបង្កើនបន្ទុកចំណាយថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានតាមវិធីជាច្រើន។ ឧទាហរណ៍ ការតម្រូវដែលមន្ត្រីគ្រប់គ្រងការដោះលែងសាកល្បងនៃខោនធីស្វែងរកការផ្លាស់ប្តូរលក្ខខណ្ឌនៃការត្រួតពិនិត្យសម្រាប់ជនល្មើសដែលស្ថិតនៅលើ PRCS ដែលបានបំពានវាជាលើកទីបី អាចនឹងបង្កើនចំនួនអ្នកជាប់ពន្ធនាគារខោនធី ប្រសិនបើលក្ខខណ្ឌនេះបណ្តាលឲ្យមានជនល្មើសកាន់តែច្រើនត្រូវបានដាក់ក្នុងពន្ធនាគារ។
- ទីបី ការផ្លាស់ប្តូរដែលបានធ្វើឡើងទៅលើសំណើដំណើរការពិចារណាការដោះលែងក្នុងប្រជាមតិ 57 នឹងបង្កើននូវបន្ទុកចំណាយថ្នាក់រដ្ឋ ដោយការកាត់បន្ថយចំនួនអ្នកទោសដែលត្រូវបានដោះលែងចេញពីពន្ធនាគារ ហើយជាទូទៅដោយការបង្កើនការចំណាយនៃដំណើរការនេះ។

យើងប៉ាន់ស្មានថា មនុស្សជាច្រើនពាន់នាក់ នឹងរងការប៉ះពាល់ដោយសំណើប្រជាមតិនេះជារៀងរាល់ឆ្នាំ។ ជាលទ្ធផល យើងប៉ាន់ស្មានថា កំណើនបន្ទុកចំណាយ **នៅថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន ទំនងជានឹងស្ថិតក្នុងចំនួនរាប់សិបលានដុល្លារក្នុងមួយឆ្នាំ**។ កំណើនជាក់ស្តែងនឹងអាស្រ័យទៅលើកត្តាមិនជាក់លាក់ជាច្រើនដូចជា ចំនួនជាក់លាក់នៃមនុស្សដែលរងការប៉ះពាល់ដោយសំណើរប្រជាមតិនេះ។

20

## ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ



***បន្ទុកចំណាយដែលពាក់ព័ន្ធនឹងតុលាការថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។*** សំណើប្រជាមតិ នឹងបង្កើនបន្ទុកចំណាយពាក់ព័ន្ធនឹងតុលាការនៅថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។ នេះគឺដោយសារតែវានឹងបណ្តាលឲ្យមានជនល្មើសមួយចំនួន ដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋដោយសារបទល្មើសពាក់ព័ន្ធនឹងចោរកម្មមួយចំនួន ជំនួសឲ្យបទមជ្ឈិម។ ដោយសារបទឧក្រិដ្ឋចំណាយពេលវេលាសម្រាប់ឲ្យតុលាការដោះស្រាយយូរជាងបទមជ្ឈិម បន្ទុកការងារសម្រាប់តុលាការ រដ្ឋអាជ្ញានៃខោនធី និងអ្នកការពារក្តីសាធារណៈ និងនគរបាលខោនធី (ដែលផ្តល់សន្តិសុខក្នុងតុលាការ) នឹងកើនឡើង។ បន្ថែមពីលើនេះ ការតម្រូវឲ្យមន្ត្រីគ្រប់គ្រងការដោះលែងសាកល្បងស្នើសុំឲ្យចៅក្រមផ្លាស់ប្តូរលក្ខខណ្ឌនៃការត្រួតពិនិត្យសម្រាប់ជនល្មើសដែលស្ថិតក្រោម PRCS បន្ទាប់ពីការបំពានជាលើកទីបី នឹងបណ្តាលឲ្យមានបន្ទុកការងារតុលាការបន្ថែមទៀត។ យើងប៉ាន់ស្មានថា បន្ទុកចំណាយពាក់ព័ន្ធនឹងតុលាការ **ទាំងនេះ អាចលើសពីបីបួនលានដុល្លារក្នុងមួយឆ្នាំ**អាស្រ័យទៅលើចំនួនជាក់ស្តែងនៃមនុស្សដែលរងការប៉ះពាល់ដោយសំណើប្រជាមតិនេះ។

***បន្ទុកចំណាយលើទីភ្នាក់ងារអនុវត្តច្បាប់ថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។*** សំណើប្រជាមតិនេះ នឹងបង្កើនបន្ទុកចំណាយលើទីភ្នាក់ងារអនុវត្តន៍ច្បាប់ថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានដោយការពង្រីកចំនួនមនុស្សដែលត្រូវបានតម្រូវឲ្យផ្តល់សំណាក DNA អាចនឹងកើនឡើងរាប់សិបពាន់នាក់ក្នុងមួយឆ្នាំ។ យើងប៉ាន់ស្មានថា កំណើន **បន្ទុកចំណាយលើទីភ្នាក់ងារអនុវត្តច្បាប់ថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន ទំនងជានឹងមិនលើសពីពីរបីលានដុល្លារក្នុងមួយឆ្នាំឡើយ។**

***ផលប៉ះពាល់សារពើពន្ធផ្សេងៗ។*** អាចនឹងមានផលប៉ះពាល់សារពើពន្ធដែលមិនបានដឹងទៅលើរដ្ឋាភិបាលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានដោយសារសំណើប្រជាមតិនេះ។ ឧទាហរណ៍ ប្រសិនបើកំណើនទោសបញ្ញត្តិកាត់បន្ថយបទល្មើសនោះ បន្ទុកចំណាយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌមួយចំនួនអាចចៀសវាងបាន។ កម្រិតដែលផលប៉ះពាល់នេះ ឬផលប៉ះពាល់ផ្សេងៗនឹងកើតឡើងពុំត្រូវបានដឹងឡើយ។

**ចូលមើល *http://cal-access.sos.ca.gov/campaign/measures/* សម្រាប់បញ្ជី នៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។**

**ចូលមើល *http://www.fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលប្រើអ្នករួមបរិច្ចាកទានកំពូលៗទាំង 10 រូបសម្រាប់គណៈកម្មការ។**

**ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋនេះ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។**